ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៩៦ កណហ

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ចូល
លេខ: ១៦៧ ៧៣
ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០២៣
បញ្ជូនមកពី [illegible]

# កំណត់ហេតុ

ថ្ងៃពុធដប់មួយកើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីម្ភៃប្រាំ ខែតុលា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងដប់ប្រាំ និងដប់ប្រាំនាទីរសៀល នៅសាលប្រជុំខេត្តត្បូងឃ្មុំ ទីស្ដីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិនិត្យ និងពិភាក្សាបញ្ចប់លើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុច ចាន់ណូរ៉ា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** ។

**សមាសភាពអញ្ជើញចូលរួមកិច្ចប្រជុំ៖**

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ី | សុខឃី | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ២. | ឯកឧត្តម ឧត្តមអគ្គានុរក្ស.១ | សន | កែវ | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ |
| ៣. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ហួច | លេនីន | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៤. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ឹម | ប្រុណិតា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៥. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | សាន | សុធន | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ |
| ៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | ធូ | សារឿន | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន |
| ៧. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | និត្យ | វិសិដ្ឋ | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន |
| ៨. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | ប៉េង | គង់ | អនុប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ |
| ៩. | លោក ឧត្តមសេនីយ៍ត្រី | ឈឹម | សម្បត្តិ | អនុប្រធាននាយកដ្ឋានរដ្ឋបាលសរុប នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១០. | លោកស្រី វរសេនីយ៍ឯក | ថោង | សុវត្ថិ | អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការ គ.ជ.ប.ជ |
| ១១. | លោក វរសេនីយ៍ឯក | អឿ | ឡេលីនដា | អនុប្រធាននាយកដ្ឋានទទួលពាក្យបណ្ដឹង នៃអគ្គាធិការដ្ឋាន |
| ១២. | លោក | ទ៉ែត | សាគុណ | ប្រធានការិយាល័យកិច្ចសហប្រតិបត្តិការ នៃអគ្គនាយកដ្ឋានរដ្ឋបាល |
| ១៣. | លោក វរសេនីយ៍ទោ | អេង | សុខគឹម | នាយការិយាល័យនីតិកម្ម នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៤. | លោកស្រី | ទ៉ាន់នី | សុភីដាវ | ប្រធានការិយាល័យស្ដីទី នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៥. | លោកស្រី | ព្រុំ | ស្នូនសត្យា | អនុប្រធានការិយាល័យ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៦. | លោក វរសេនីយ៍ត្រី | ផុន | ស៊ុនលី | នាយផ្នែក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១៧. | លោក វរសេនីយ៍ឯក | ឡឿន | ឧត្ដម | អនុប្រធាននាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |
| ១៨. | លោក វរសេនីយ៍ទោ | ម៉ៅ | ផល្លីន | នាយរងការិយាល័យ នៃនាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |
| ១៩. | លោក វរសេនីយ៍ទោ | សៅ | សម្បត្តិ | នាយរងការិយាល័យ នៃនាយកដ្ឋានសរុប និងស្ថិតិ (លេខាកត់ត្រា) |

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តម អ៊ុច ចាន់ណារ៉ា អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** និងជាប្រធានអង្គប្រជុំ បានមានប្រសាសន៍ស្វាគមន៍ ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាជិក សមាជិកា និងបើកអង្គប្រជុំតាមប្រព័ន្ធហ្ស៊ូម ជាមួយភាគីនីហ្សេរីយ៉ា ដើម្បីបន្តពិនិត្យ និងពិភាក្សាបញ្ចប់លើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការ អនុវត្តច្បាប់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា។ បន្ទាប់មក **ឯកឧត្តម ប្រធានអង្គប្រជុំ** បានស្នើសមាជិក សមាជិកា នៃអង្គប្រជុំចូលរួមមតិយោបល់ផ្ទៃក្នុងចាប់ពីមាត្រា១ ដល់មាត្រា១៤ មុននឹងដាក់ជូនភាគីនីហ្សេរីយ៉ាពិនិត្យ និងពិភាក្សាបន្ត។

ក្រោយពីភាគីនៃប្រទេសទាំងពីរបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេច កែសម្រួលពាក្យពេចន៍ បំពេញបន្ថែម ឬ លុបចោលខ្លឹមសារមួយចំនួន ចាប់ពីចំណងជើង ដល់ត្រឹមមាត្រា ៦ ដូចខាងក្រោម ៖

**ចំណងជើង**

នៅពីក្រោមពាក្យ (BETWEEN) លុបពាក្យ (~~THE KINGDOM OF CAMBODIA~~) ជំនួសមកវិញនូវពាក្យ (THE GOVERNMENT OF THE KINGDOM OF CAMBODIA) និងនៅពីក្រោមពាក្យ (~~THE FEDERAL REPUBLIC OF NIGERIA~~) ជំនួសមកវិញនូវពាក្យ (THE GOVERNMENT OF THE FEDERAL REPUBLIC OF NIGERIA ។

**មាត្រា១**

ឯកភាពគ្នាលុបចេញខ្លឹមសារទាំងស្រុងដែលបន្ថែមដោយភាគីនីហ្សេរីយ៉ា។

**មាត្រា២**

ឯកភាពគ្នាយកទាំងស្រុង ។

**មាត្រា៣**

ចំណុចទី២ ឯកភាពគ្នាយកទាំងស្រុង ។

ចំណុចទី៣ ភាគីទាំងពីរឯកភាពលុបពាក្យ (~~The party to whom the request~~) ជំនួសមកវិញនូវពាក្យ (The requested party) ដែលជាឃ្លាដើមរបស់ភាគីកម្ពុជា ។

**មាត្រា៤**

ភាគីទាំងពីរ បានឯកភាពគ្នាកាត់យកចំណុចទី៦ពីមាត្រា២ចាស់ មកបង្កើតជាមាត្រា៤ថ្មី ។

**មាត្រា៥**

ចំណុចទី១ នៅពីក្រោយពាក្យ (Understanding) លុបពាក្យ (~~Will~~) ជំនួសមកវិញនូវពាក្យ (Sall) ។

ចំណុចទី៣ នៅពីក្រោយពាក្យ (This obligation) លុបពាក្យ (~~Will~~) ជំនួសមកវិញនូវពាក្យ (Sall) ។

ចំណុចទី៤ នៅពីក្រោយពាក្យ (This party) លុបពាក្យ (~~Will~~) ជំនួសមកវិញនូវពាក្យ (Sall) និងបន្ថែមអក្សរ (S) នៅពីក្រោយពាក្យ (Purpose) ។

**មាត្រា៦**

អាស្រ័យដោយពេលវេលា និងយោងតាមការជជែកពិភាក្សារបស់ភាគីទាំងពីរ មិនទាន់ឯកភាពគ្នាអង្គប្រជុំបានសម្រេចលើកពេលប្រជុំទៅពេលក្រោយ ដើម្បីទុកពេលឱ្យភាគីទាំងពីរជជែកពិភាក្សាផ្ទៃក្នុងបន្ថែម លើមាត្រា

បន្តបន្ទាប់ ទើបភាគីទាំងពីរនឹងត្រូវជួបប្រជុំតាមប្រព័ន្ធហ្ស៊ូមជាបន្តទៀត។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាស រីករាយស្និទ្ធស្នាល និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ ចន្ទ ១ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០២៣

**អ្នកធ្វើកំណត់ហេតុ**

**វរសេនីយ៍ឯក ឡឿន ឧត្តម**

**បានឃើញ និងឯកភាព**

ថ្ងៃ ព្រហស្បតិ៍ ៤ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**ប្រធានអង្គប្រជុំ**

**អ៊ូច ចាន់ណារ៉ា**